# ប្រវត្តិសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកថ្នាក់ទី១
# គណមហានិកាយ ជោតញ្ញាណោ ព្រះនាម ជួន-ណាត

កំណាព្យពាក្យប្រាំបួន ដោយ គឹម-ច័ន្ទវង្ស
អ្នកនិពន្ធខ្មែរទទួលជ័យលាភីគុរង្វាន់ជំនាន់សុតន្តប្រីជាឥន្ទឆ្នាំ១៩៧៣
ថ្ងៃទី២០កញ្ញាឆ្នាំ១៩៩៤

| | | | |
|---|---|---|---|
| ១- | អហំយើងខ្ញុំ | សូមប្រណម្យ | ប្រណិប័តន៍ |
| | ផ្គងថ្វាយថ្វាត់ | ពីចម្ងាយ | ចំពោះអង្គ |
| | សូមគោរព | ថ្វាយបង្គំ | សម្តេចសង្ឃ |
| | ទ្រង់អគ្គ | រាជកវី | ល្បីអស្ចារ្យ ។ |
| ២- | សង្ឃនាយក | ថ្នាក់ទី១ | នាម“ជួន-ណាត” |
| | ព្រះទ័យស្អាត | ចិត្តបរិសុទ្ធ | ប្រោសមេត្តា |
| | យើងស្រឡាញ់ | ទុកព្រះអង្គ | ជាអាចារ្យ |
| | មានប្រាថ្នា | ចង់ថែវង្ស | អង្គប្រាជ្ញនេះ ។ |
| ៣- | ក្នុងពេលនេះ | ខ្ញុំសម្តែង | រៀបប្រវត្តិ |
| | របស់ទ្រង់ | តាមកំណត់ | ខ្ញុំចាំចេះ |
| | ទុកឲ្យក្មួន | ចៅជាន់ក្រោយ | ជាចំណេះ |
| | ថាអង្គនេះ | ជាអ្នកប្រាជ្ញ | រាជកវី ។ |
| ៤- | ទ្រង់ប្រសូត្រ | ដប់មួយរោច | ខែមីនា |
| | ថ្ងៃអង្គារ | ដែលត្រូវជា | ខែទីបី |
| | ចន្ទគតិ | ដប់ប្រាំបី(១៨) | ប៉ែតសិបបី(៨៣) |
| | គងពិសី | កំពង់ស្ពឺ | រកាកោះ ។ |
| ៥- | ភូមិកំរៀង | ព្រះបិតា | នាមហៅជួន |
| | និងភរិយា | សមសុទ្ធិសួន | ទ្រង់នាមឈ្មោះ |
| | ហៅថាយក់ | មានបុត្រពីរ | ដោយចំពោះ |
| | គឺសម្តេច | ម្នាក់ទៀតឈ្មោះ | លោកជួន-នុត ។ |

៦- កាលកុមារ បានសិក្សា អក្សរសាស្ត្រ
ចេះចាំច្បាស់ លេខនព្វន្ត ច្រើនបំផុត
កបលក្ខណា សមលក្ខណៈ ជាកុលបុត្ត
មាននិស្ស័យ ខ្ពស់បំផុត នឹងសាសនា ។

៧- ពេលព្រះជន្ម ១៤ឆ្នាំ ទ្រង់ព្រះផ្នួស
បានចូលបួស ជាសាមណេរ ក្នុងវស្សា
ដប់ប្រាំបី(១៨) កៅប្រាំពីរ(៩៧) សំរិទ្ធិកា
ពិសាខា នាឆ្នាំច ១៥កើត ។

៨- នៅពោល្យំ រលាំងកែន កណ្តាលស្ទឹង
ខេត្តកណ្តាល ជាពំនឹង និងកំណើត
ការសិក្សា បានចេះដឹង មួយដឺឆើត
ធ្វើឲ្យកើត ជាអ្នកប្រាជ្ញ យ៉ាងពេញលេញ ។

៩- បួសពីរឆ្នាំ ក៏ចូលរៀន ព្រះបរិយត្តិ
នៅក្នុងវត្ត ឧណ្ណាលោម ក្រុងភ្នំពេញ
ដល់វស្សា ២១ឆ្នាំ បានបំពេញ
ភិក្ខុវិញ ដប់ប្រាំបួន(១៩) សូន្យប្រាំមួយ(០៦) ។

១០- ត្រូវខែជេស្ឋ ១៤កើត នាឆ្នាំរោង
តាមលេខយោង ឆសករាជ ស័កប្រាំមួយ
ទ្រង់ព្រះផ្នួស គឺទ្រង់បួស ក្នុងពុទ្ធត្រួយ
ដែលលើកស្ទួយ ដោយឧបជ្ឈាយ៍ នាមម៉ា-កេត ។

១១- ព្រះកែ-ម៉ម ធម្មវាចា គ្រូសូត្រស្តាំ
តាមលំនាំ ពុទ្ធសាសនា ពុទ្ធខេត្ត
គ្រូសូត្រឆ្វេង ព្រះអ៊ុន-ខឹម សក្យវេទ
បុញ្ញខេត្ត អនុស្សា វនាចារ្យ ។

១២- លុះព្រះអង្គ ទ្រង់ព្រះផ្នួស ភិក្ខុហើយ
មិនកន្តើយ ទ្រង់បាននាម បញ្ញត្តិថា
ជោតញ្ញាណ គឺបញ្ញា ដ៏ថ្លៃថ្លា
ទ្រង់សិក្សា បានសម្រេច ដូចប៉ុនប៉ង ។

១៣- និស្ស័យក្រាស់ ទ្រង់យល់ច្បាស់ ពុទ្ធសាសនា
ចិត្តជ្រះថ្លា ខំសិក្សា តាមបំណង
មានថានៈ ចំណេះដឹង ជាចម្បង
អស់លោកផង គោរពទ្រង់ ហើយកោតខ្លាច ។

១៤- ទ្រង់ចេះចាំ យល់ឬសគល់ ច្រើនភាសា
លាវភូមា មនសៀមខ្មែរ យ៉ាងអង់អាច
សំស្ក្រឹត និងបាលី ព្រះទ័យស្វាច
ដូចអ្នកប្រាជ្ញ រាជបណ្ឌិត ផងនានា ។

១៥- ក្នុងព.ស. ម្ភៃបួន(២៤) ហុកប្រាំមួយ(៦៦)
ទៅហាណូយ ទ្រង់បំពេញ ខាងភាសា
សំស្ក្រឹត និងអក្សរ សិលាចារ
គឺភាសា តាមផ្ទាំងថ្ម នាបូរាណ ។

១៦- ទ្រង់ស្នាក់នៅ នឹងអាចារ្យ បារាំងសែស
នៅប្រទេស យួនខាងជើង ពីរអង្គប្រាណ
គឺសម្តេច នាមហ្វួត-តាត ចេះចំណាន
អាចអានបាន ភាសាថ្ម អង្គរវត្ត។

១៧- ល្វី-ហ្វី-ណូត៏ បារាំងសែស ជាចាងហ្វាង
និងជំណាង ចៅហ្វាយខ្មែរ តាមប្រវត្តិ
ជាអាចារ្យ បានបង្រៀន ឲ្យប្រាកដ
ទ្រង់ហ្មត់ចត់ ទាំងភាសា វៀតណាមទៀត ។

១៨- ខាងភាសា បារាំងសែស និងអង់គ្លេស
ទ្រង់ក៏ចេះ ល្មមប្រាស្រ័យ មិនឃ្លៀងឃ្លាត
ចេះវែកញែក រកឬសគល់ ភាសាជាតិ
ចែកផៅញាតិ កូនចៅក្រោយ បានសិក្សា ។

១៩- នៅក្នុងឆ្នាំ ដប់ប្រាំបួន(១៩) សាមសិបមួយ(៣១)
ទ្រង់ទៅជួយ និងប្រជុំ ពិភក្សា
នៅវៀងចន្ទន៍ ហ្លួងព្រះបាង ខាងសាសនា
ផ្នែកសិក្សា សាលារង ខាងបាលី ។

| | | | |
|---|---|---|---|
| ២០- | ឆ្នាំសាមបី(៣៣) | ទ្រង់បាននាំ | ប្រតិភូ |
| | ព្រះសង្ឃខ្មែរ | អង្គគ្រូៗ | អង្គមន្ត្រី |
| | និមន្តទៅ | កូសាំងស៊ីន | ជាសាក្សី |
| | ត្រួតពិនិត្យ | វត្តចាស់ថ្មី | ខេត្តនានា ។ |
| ២១- | វិរិយភាព | ក្នុងកិច្ចការ | ដ៏ធំៗ |
| | ទ្រង់បន្ទំ | ហើយទ្រង់ឡើង | យសសក្តិងារ |
| | សមណសក្តិ | តាមលំដាប់ | ផងនានា |
| | ក្នុងសាសនា | ព្រះពុទ្ធអង្គ | របស់យើង ។ |
| ២២- | ម្ភៃបួន(២៤) | ហាសិបបួន(៥៤) | ពុទ្ធសករាជ |
| | រដ្ឋអំណាច | បានប្រគេន | លើកតម្កើង |
| | ជាបាឡាត់ | សក្យបុត្ត | ថានៈថ្កើង |
| | ដូចគេយើង | ធ្លាប់បានដឹង | មកយូរយារ ។ |
| ២៣- | ក្នុងព.ស. | ម្ភៃបួន(២៤) | ហាសិបប្រាំមួយ(៥៦) |
| | រដ្ឋលើកស្ទួយ | ជាព្រះគ្រូ | សង្ឃសត្ថា |
| | នៃសម្តេច | ព្រះនាមទៀង | សង្ឃរាជា |
| | ទីថានា | សម្រាប់ឯក | សម្តេចសង្ឃ ។ |
| ២៤- | ឆ្នាំម្ភៃបួន(២៤) | ចិតសិបប្រាំ(៧៥) | បានឡើងជា |
| | ព្រះរាជា | កត្តិយស | មន្ត្រីសង្ឃ |
| | គឺព្រះសាស | នសោភ័ណ | តំណវង្ស |
| | ផ្នែកព្រះសង្ឃ | ក្នុងពុទ្ធសាសន៍ | តរៀងទៅ ។ |
| ២៥- | បន្ទាប់ទៀត | ទ្រង់បានឡើង | ពុទ្ធឃោសា |
| | ចារិយវង្ស | រាជគណៈ | លំដាប់ទោ |
| | តាមសមសួន | ជិតផុតថ្នាក់ | ដែលតម្រូវ |
| | នៅក្នុងឆ្នាំ | ម្ភៃបួន(២៤) | ប៉ែតសិបបួន(៨៤) ។ |
| ២៦- | លុះក្នុងឆ្នាំ | ម្ភៃបួន(២៤) | ប៉ែតសិបប្រាំបី(៨៨) |
| | ឡើងមន្ត្រី | គណៈឯក | ដោយសមសួន |
| | ជាពោធិវង្ស | ដប់ប្រាំបួន(១៩) | សែសិបបួន(៤៤) |
| | ចាប់ពាក្យចួន | ត្រូវគ.ស. | គ្រឹស្តសករាជ ។ |

| | | | | |
|---|---|---|---|---|
| ២៧- | ឆ្នាំម្ភៃបួន(២៤) | កៅសិបពីរ(៩២) | ជាអធិបតី | |
| | អស់មន្ត្រី | សង្ឃទាំងពួង | គឺសង្ឃរាជ | |
| | មានព្រះនាម | ល្បីរន្ទឺ | ភ្លឺសស្វាច | |
| | ជាសង្ឃរាជ | ព្រះមហាសុ | មេធាធិបតី | ។ |
| ២៨- | សង្ឃនាយក | ផ្នែកគណៈ | មហានិកាយ | |
| | ដូចបរិយាយ | ជូនហូរហែរ | តាមករី | |
| | ដែលស្រាវជ្រាវ | ជាសណ្តាប់ | ប្រាប់ប្រុសស្រី | |
| | តាមសម្តី | បើមានខ្វះ | ជួយសំបាច់ | ។ |
| ២៩- | ម្ភៃបួន(២៤) | កៅសិបបួន(៩៤) | ក្នុងឆ្នាំនេះ | |
| | រាជតម្រិះ | តំឡើងសក្តិ | ជាសម្តេច | |
| | ព្រះមហាសុ | មេធាធិបតី | ដែលជាស្តេច | |
| | សង្ឃនាយក | លើសអស់សង្ឃ | នៃកម្ពុជា | ។ |
| ៣០- | សម្តេចសង្ឃ | ទ្រង់មិនល្បី | តែក្នុងស្រុក | |
| | ទោះក្រៅស្រុក | ទ្រង់ក៏ល្បី | ដូចភូមា | |
| | គេឲ្យសក្តិ | ប្រទានយស | ដ៏ថ្លៃថ្លា | |
| | អគ្គមហា | ព្រះបណ្ឌិត | សហភាព | ។ |
| ៣១- | នៅក្នុងឆ្នាំ | ម្ភៃបួន(២៤) | កៅប្រាំបី(៩៨) | |
| | លើសមន្ត្រី | សង្ឃនានា | លើផ្ទៃរាប | |
| | នៃប្រទេស | ជាតិភូមា | សហភាព | |
| | សូមជម្រាប | កត្តិយសល្បី | នៃព្រះអង្គ | ។ |
| ៣២- | លក្ខណៈទ្រង់ | ជាអ្នកប្រាជ្ញ | រាជបណ្ឌិត | |
| | ល្បីឈ្មោះពិត | សមចំណោះ | ទ្រង់ជាស្តេច | |
| | តែក្នុងស្រុក | ហាក់ព្រងើយ | ខ្លាចទ្រង់ដាច់ | |
| | មិនលើកទ្រង់ | ឲ្យសូរេច | រាជករី ។ | |
| ៣៣- | ជនជាតិគេ | ខ្លាចទ្រង់ញ័រ | ព្រោះទ្រង់ចេះ | |
| | មានចំណោះ | លើសអស់ជន | ទាំងប្រុសប្រ៊ | |
| | តែជាតិខ្មែរ | អ្នកដឹកនាំ | គំនឹតខ្ជី | |
| | ខ្លាចទ្រង់ល្បី | អាប់រាសី | របស់ខ្លួន | ។ |

| | | | |
|---|---|---|---|
| ៣៤- | ខ្មែរខ្លាំងណាស់ | ខាងខ្លួនល្ងង់ | ធ្វើជាចេះ |
| | ខ្លួនមិនខ្មេះ | អួតក្អេងក្អាង | បំពើងខ្លួន |
| | អ្នកណាចេះ | ចង់រំលាយ | ជាក្រមួន |
| | ឲ្យគេថា | មានតែខ្លួន | លើសគេឯង ។ |
| ៣៥- | នេះហើយខ្មែរ | ល្ងង់ធ្វើចេះ | មិនជួយគ្នា |
| | ខ្លួនប្រជា | ធ្វើជាស្តេច | ស្រែកក្តែងៗ |
| | អញ្ជឹងហើយ | បានជាខ្មែរ | អស់សម្បែង |
| | ព្រោះចេះឯង | មិនព្រមក្រែង | ចេះគេផង ។ |
| ៣៦- | ប្រទេសគេ | ឃើញអ្នកចេះ | រាប់អានណាស់ |
| | ខំខ្វេះខ្វះ | លើកតម្កើង | ក្រៃកន្លង |
| | ឲ្យកិត្តិយស | ដ៏ខ្ពង់ខ្ពស់ | មិនឲ្យហ្មង |
| | លើសរាស្ត្រផង | គ្មានប្រណែន | បន្តិចសោះ ។ |
| ៣៧- | លុះដល់ឆ្នាំ | ម្ភៃប្រាំ(២៥) | ស៊េរីមួយ(០១) |
| | គេលើកស្ទួយ | លើសគេឯង | រដ្ឋបុរស |
| | អភិធជ | មហារដ្ឋគរុ | ដ៏ត្រង់ស្មោះ |
| | លើបុរស | មានមួយអង្គ | នៃភូមា ។ |
| ៣៨- | ខែកុម្ភៈ | ដប់ប្រាំបួន(១៩) | ហុកសិបបួន(៦៤) |
| | ដោយគាប់ជួន | ពួកនិពន្ធ | ខ្មែរស្រុះគ្នា |
| | បានសម្រេច | លើកតម្កើង | ព្រះអង្គជា |
| | ក្នុងថានា | ព្រះអគ្គ | និពន្ធខ្មែរ ។ |
| ៣៩- | ហើយបានថ្វាយ | សមាជិក | ដ៏ខ្ពង់ខ្ពស់ |
| | ជាកិត្តិយស | សមាគម | និពន្ធខ្មែរ |
| | ដូចរៀបរាប់ | ប្រាប់បងប្អូន | ជាហូរហែរ |
| | សូមជួយកែ | ជួយតម្រង់ | ជួយលើកស្ទួយ ។ |
| ៤០- | ឆ្នាំម្ភៃប្រាំ(២៥) | សូន្យប្រាំពីរ(០៧) | ឡើងសម្រេច |
| | ជាសម្តេច | សង្ឃនាយក | ថ្នាក់ទីមួយ |
| | ផ្នែកគណៈ | មហានិកាយ | មានតែមួយ |
| | ការលើកស្ទួយ | សមថានៈ | ព្រះអង្គណាស់ ។ |

៤១- ហុកប្រាំពីរ(៦៧) ឧសភា ម្ភៃប្រាំបី(២៨)
ក្នុងនាមនៃ មហាវិទ្យាល័យ អក្សរសាស្ត្រ
ជាសាលា ភូមិន្ទសាកល មនុស្សសាស្ត្រ
ស្ដេចអម្ចាស់ សីហនុ ទ្រង់ប្រទាន ។
៤២- សញ្ញាបត្រ មហាបណ្ឌិត អក្សរសាស្ត្រ
បានប្រកាស យ៉ាងឱឡារ សព្វទីថាន
ប្រជាពល មានអំណរ ពន់ប្រមាណ
ឃើញទ្រង់បាន គ្មានប្រណែន ដូចអ្នកផង ។
៤៣- ខ្លះពេបជ្រាយ មិនសប្បាយ ប្រកាន់បក្ស
ខ្លះប្រកាន់ អាងវណ្ណៈ ថាអ្នកខ្ពង់
មិននាំគ្នា ខំកែកុន ជួយតម្រង់
ឲ្យបានត្រង់ បែរយកលែស សំ.បាលី ។
៤៤- វត្តនានា ជាទូទៅ ក្នុងកម្ពុជា
បាននាំគ្នា ធ្វើបុណ្យទាន ថ្វាយសួស្ដី
ថ្វាយព្រះអង្គ មានជន្មា សុខសេរី
បានយឺនយូរ មានរស្មី កុំបីខាន ។
៤៥- ព្រះអង្គជា ជាតិបិតា អក្សរសាស្ត្រ
ពូកែណាស់ ខាងវែកញែក រកលក្ខណ៍ថាន
មូលឫសគល់ អក្សរខ្មែរ យ៉ាងចំណាន
ទុកស្នាដៃ ឯកសណ្ឋាន អក្សរខ្មែរ ។
៤៦- ទ្រង់និពន្ធ ពាក្យកំណាព្យ ជាកាព្យឃ្លោង
យកន័យយោង ប្រដៅសត្វ ឲ្យកែប្រែ
ហើយនិពន្ធ វចនា នុក្រមខ្មែរ
វែកញែកកែ អក្សរសាស្ត្រ ឲ្យរុងរឿង ។
៤៧- ទ្រង់និពន្ធ វេយ្យាករណ៍ ជាបាលី
ឲ្យប្រុសស្រី បានសិក្សា ចំណេះថ្កើង
បានជួយជាតិ រួមខ្មីឃ្មាត លើកតម្កើង
បំផុះយើង ឲ្យចេះគិត គំនិតថ្កាន ។

៤៨- ព្រះសម្ពុទ្ធ ទ្រង់សម្តែង ពីជីវិត
គ្មានអ្វីពិត អនិច្ចំ សច្ចៈបាន
សព្វមនុស្សសត្វ តែងកើតមក គ្រប់ៗប្រាណ
តោងរលត់ អវសាន ទីបំផុត ។

៤៩- ពេលរសៀល ថ្ងៃអង្គារ ១២កើត
គឺខាងខ្នើត ខែភ្លឺស្វាង នៃភទ្របទ
ឆ្នាំរការ ឯកស័ក គួររន្ធត់
ទ្រង់ឪសថ គឺប្រឈួន រោគប្រចាំ ។

៥០- ត្រូវនឹងថ្ងៃ ទីម្ភៃបី(២៣) ខែកញ្ញា
នៅវេលា ម៉ោងដប់ប្រាំ(១៥) សែសិបប្រាំ(៤៥)
គ្រូចំណាន បានព្យាបាល យ៉ាងសកម្ម
ប្រកបថ្នាំ រហូតមក តែអនិច្ចា ។

៥១- លុះដល់ថ្ងៃ ដប់បួន(១៤)កើត ទីម្ភៃប្រាំ(២៥)
ខែកញ្ញា ហុកប្រាំបួន(៦៩) ព្រះអស្សា
សប្បស្សាស ក៏ឃ្លាតចាក ព្រះកាយា
គ្មានអ្នកណា មួយជឿឡើយ ក្នុងពេលនោះ ។

៥២- នៅម៉ោងម្ភៃ(២០) ម្ភៃ(២០)នាទី សម្តេចសង្ឃ
នាមជួន-ណាត ព្រះអង្គទ្រង់ បានទម្លុះ
វិញ្ញាណក្ខន្ធ ទីវង្គត នាគ្រានោះ
ធ្វើឲ្យមនុស្ស ក្នុងកម្ពុជា សែនសង្វេគ ។

៥៣- ស្តាយអើយស្តាយ មិនគួរឆ្ងាយ ខានឃើញភក្ត្រ
បាត់សម្តី កបវរលក្ខណ៍ ធ្លាប់តែស្រែក
ប្រៀនប្រដៅ ដល់កូនចៅ មិនអល់ឯក
ប្រជាពល ស្តាយអនេក ចំពោះទ្រង់ ។

៥៤- ហេតុអស្ចារ្យ នាគ្រានោះ កក្រើកដី
គ្រប់វត្តវ៉ា ទូងស្គរជ័យ ថ្វាយដល់ទ្រង់
ទោះសព្វសត្វ មនុស្សទូទៅ គ្រហស្ថសង្ឃ
បានកាន់ទុក្ខ ថ្វាយដល់ទ្រង់ ដោយជ្រះថ្លា ។

៥៥- ក្នុងជីវិត កាលពីតូច រហូតធំ
ដួងចិត្តខ្ញុំ សែនក្ដុលក្ដួល អួលឱរា
មិនធ្លាប់ដឹង មិនធ្លាប់ឃើញ ហេតុអស្ចារ្យ
នេះហៅថា កក្រើកដី កក្រើកទឹក ។

៥៦- ទាំងក្មេងចាស់ មាត់ឆ្លើយឆ្លង សួរនាំគ្នា
វត្តនានា បានប្រារព្ធ បុណ្យរំលឹក
ថ្វាយព្រះអង្គ សព្វទិសទី យ៉ាងភ្លូកភ្លឹក
អឹកអធឹក សូមឲ្យទ្រង់ សុខតទៅ ។

៥៧- ហេតុអស្ចារ្យ ក្នុងជីវិត គ្រាទី១
ខ្ញុំបានឃើញ ហេតុរញ្ជួយ ទ្រូងអួលក្ដៅ
ចិត្តអារម្មណ៍ ត្រសែតហើរ ហាក់មួមៅ
គឺសំដៅ ទ្រង់សុគត នេះតែម្ដង ។

៥៨- ហេតុទីពីរ ដែលអស្ចារ្យ ខ្ញុំឃើញច្បាស់
គឺប្រទះ យង់យល់ជាក់ កងរំពង
នៅសហរដ្ឋ អាមេរិក នេះឯងហោង
គួរចាំចង ក្នុងជីវិត គ្រប់ៗគ្នា ។

៥៩- នៅពេលយួន រំលោភខ្មែរ ប៉ែតប្រាំបួន(៨៩)
ខែមករា ចូលរុកគួន ខាងរដ្ឋា
អាមេរិក បានផ្សព្វផ្សាយ សព្វទិសា
ខ្មែរវេទនា រងខ្លោចផ្សា វិនាសកម្ម ។

៦០- គ្រប់ទូរទស្សន៍ គ្រប់វិទ្យុ សារពត៌មាន
រដ្ឋក៏បាន ថ្កោលទោសយួន យ៉ាងសកម្ម
ទោះក្មេងចាស់ បានឃើញឮ ហើយចងចាំ
វិនាសកម្ម របស់ខ្មែរ សែនរញ្ជួយ ។

៦១- ខ្ញុំបានរួម ជាតំណាង របស់ខ្មែរ
ជាហូរហែរ ទៅអង្គាស ប្រាក់ជំនួយ
បានច្រើនលាន ឲ្យអង្គការ យកទៅជួយ
ខ្មែររងួយ ឯជំរុំ ប្រទេសថៃ ។

៦២- សហរដ្ឋ អាមេរិក បានចាត់ការ
ដាក់ផែនការណ៍ គ្រប់ទិសទី ប្រចាំថ្ងៃ
គឺទាំងរដ្ឋ ទាំងអង្គការ គ្មានសំចៃ
បានថ្កោលទោស បនប្រល័យ ទាំងយួនខ្មែរ ។

៦៣- ខ្លោចផ្សាអើយ សែនខ្លោចផ្សា ចិត្តក្តុកក្តួល
សែនរញ្ជួល ខ្មែរវេទនា គ្មានពេលល្ហែ
បនប៉ុល-ពត បានធ្វើបាប ដល់រាស្ត្រខ្មែរ
យួនក៏ដែរ ផ្សំនឹងខ្មែរ មួយបក្សទៀត ។

៦៤- ឯបារាំង ជាចៅហ្វាយ របស់ខ្មែរ
លុះមួយខែ ទើបផ្សព្វផ្សាយ អមព្រោងព្រាត
នេះចៅហ្វាយ ១០០ឆ្នាំ ជិះចោលម្យៀត
សូមអស់ញាតិ ជួយចងចាំ ក្នុងចិន្តា ។

៦៥- ឥឡូវបែរ ងាកចូលមក សម្តេចសង្ឃ
ដែលព្រះអង្គ ទ្រង់សុគត យើងកំព្រា
ចិត្តម្នាក់ៗ នៅអាល័យ គ្រប់ៗគ្រា
យើងរាល់គ្នា មានទោមនស្ស ជារាល់ថ្ងៃ ។

៦៦- បុណ្យកុសល ទាំងប៉ុន្មាន ដែលយើងមាន
សូមទ្រង់បាន ជាចំណែក ជាបច្ច័យ
សូមថ្វាយទ្រង់ សូមឲ្យទ្រង់ អស់ទុក្ខភ័យ
អស់អាល័យ ពីលោកិយ តទៅអើយ ។

៦៧- សូមព្រះអង្គ ទ្រង់បានយាង ដល់និព្វាន
កុំឲ្យមាន ឧបសគ្គអ្វី មកបៀតឡើយ
កើតជាមនុស្ស សូមខ្ពង់ខ្ពស់ កំពូលត្រើយ
គ្រាន់ជួយស្បើយ ដល់សត្វលោក ផងនានា ។

៦៨- សិស្សយើងខ្ញុំ សូមបង្គំ ពីចម្ងាយ
គ្មានអ្វីថ្វាយ មានតែបុណ្យ ទាននានា
ធ្វើបញ្ជូន ទុកជាក្បូន ពួនជាធារ
ថ្វាយរាជា ដ៏មានយស ហួសវិស័យ ។

៦៩- ពួកសិស្សគណ ឧទ្ទិស្ថាន ចំពោះទ្រង់
សូមព្រះអង្គ ងាកបែរក្រោយ ឲ្យពរជ័យ
ដល់យើងខ្ញុំ ព្រោះឥឡូវ មានទុក្ខភ័យ
ហេតុចង្រៃ កើតមានឡើង ដល់ស្រុកខ្មែរ ។

៧០- សូមពលរដ្ឋ បានក្តីសុខ មានសេរី
ពួកព្រៃផ្សៃ សូមវិនាស ជាតិកែប្រែ
មានសន្តិសុខ សុខសប្បាយ ជួបឱម៉ែ
ចម្ការស្រែ មានភោគផល ផុតទុក្ខសៀយ ។

៧១- សត្រូវមុខ សូមរំលង ខ្ទងវលាយ
បែកខ្ចាត់ខ្ចាយ កុំបៀតបៀន ដល់ខ្មែរឡើយ
កម្មអាក្រក់ ក៏សូមហ្មត់ អស់បង្ហើយ
ច្រានដល់ត្រើយ បានសុខសាន្ត ដូចទ្រង់នៅ ។

៧២- កាលពីទ្រង់ គង់ជន្មា ព្រះទ័យស្អាត
ហើយទ្រង់ឆ្លាត មានមេត្តា គ្រប់ញាតិផៅ
ជាព្រះព្រហ្ម ញញឹមព្រាយ រួសចៅរៅ
គេគាល់ហ្វៀ យកឱវាទ ពីព្រះអង្គ ។

៧៣- ព្រះអង្គទ្រង់ មានធម៌បួន ក្នុងព្រះទ័យ
ចេះកែឆ្នៃ ប៉ិនប្រសព្វ ឆ្លាតយល់យង់
ហៅពលះ គឺកម្លាំង ល្អបញ្ចង់
ទោះកាយទ្រង់ ក៏សក្តិសម អង្គអ្នកប្រាជ្ញ ។

៧៤- មួយបញ្ញា ឆ្លាតកបកល ចេះដោះស្រាយ
មិនជិនណាយ មិនចេះទាល់ ហើយអង់អាច
ក្នុងជំនុំ ទាំងតូចធំ មិនចេះខ្លាច
មានអំណាច មិនទើសទាក់ ហើយសមសួន ។

៧៥- ពីរវិរិយ គឺព្យាយាម ទាំងថ្ងៃយប់
ស្រាវជ្រាវគ្រប់ រួចបញ្ចេញ ទៅជាក្បួន
ឲ្យកូនចៅ ជំនាន់ក្រោយ បានភ្ញាក់ខ្លួន
រឹងមាំមួន គ្រប់វិស័យ កើនបញ្ញា ។

៧៦- បីអនលជ្ឈិ ប្រព្រឹត្តិល្អ ជាគម្រូ
ហើយជាគ្រូ ទូស្រុកទេស ផងនានា
ល្បីក្រៅស្រុក គេចាត់ទុក ជាអាចារ្យ
ដូចភ្នំមា ជាតឹកតាង សម្អាងហើយ ។
៧៧- ប្អូនសង្គហៈ ទ្រង់មេត្តា មិនរើសមុខ
ឲ្យគេសុខ ប្រាសចាកទុក្ខ និរាសស្បើយ
ជួយទាំងសព្វ ប្រដៅសត្វ មិនកន្តើយ
នេះឯងហើយ ហៅព្រះព្រហ្ម នាលោកិយ ។
៧៨- យើងទាំងអស់ គួរគ្រាប់តាម ហើយគោរព
ត្រូវសេពគប់ ស្តាប់អស់អាថ៌ ពាក្យសម្តី
ដែលទ្រង់ទុក ជាក្បួនខ្នាត រាជកវី
ឲ្យប្រុសស្រី បានរៀនសូត្រ ទល់សព្វថ្ងៃ ។
៧៩- ឆ្នាំចិតប្រាំបី(៧៨) ខ្ញុំមកដល់ សហរដ្ឋ
មានដំណឹង គួររន្ធត់ ស្លុតស្មារតី
ថាព្រះអង្គ ទ្រង់សុគត ព្រះជន្មខ្ស័យ
មានសង្ស័យ ថាមានគេ លួចធ្វើគត ។
៨០- ដោយដាក់ថ្នាំ ជាតិបំពុល ក្នុងក្រយា
អាចប្រហារ ឲ្យព្រះជន្ម ទ្រង់រលត់
ការនេះស្ងាត់ ហើយគេធ្វើ ដោយហ្មត់ចត់
ភ្លៃបំបត់ ថាទ្រង់ឈឺ ជម្ងឺចាស់ ។
៨១- ខ្ញុំនឹងឆេវ ខំស៊ើបសួរ ក៏មិនលិច
តែមិនភ្លេច ទុកក្នុងចិត្ត គិតយ៉ាងច្បាស់
ថ្ងៃណាមួយ គង់នឹងដឹង ឥតប្រែផ្លាស់
គង់នឹងប៉ះ ឮល្ហិចល្ហៀង មានសង្កា ។
៨២- បើសិនជា ដូចជាពាក្យ ឮនេះមែន
សូមទេវតា រាប់ម៉ឺនសែន ជួយផ្ដន្ទា
ចោរសមាន អ្នកដែលក្បត់ ឲ្យវេទនា
មានកម្មពៀរ កុំបីខាន ទៅអនាគត ។

៨៣- បើពាក្យនេះ មិនពិតវិញ ក៏សូមទោស
តែបើពិត ពិតជាខុស ពិតប្រាកដ
ហើយទោសនោះ មិនអាចគេច មិនអាចរត់
ជាទោសក្បត់ ជាតិពេញទី ត្រូវតែសង ។
៨៤- សព្វថ្ងៃនេះ ទូលបង្គំ គ្មានអ្វីស្នង
មានតែចង ប្រវត្តិទ្រង់ ប្រាប់ស្នាដៃ
ទុកជាកេរ្តិ៍ ដល់កូនចៅ លើលោកិយ
ឲ្យយល់ន័យ ថាទ្រង់នេះ អស្ចារ្យណាស់ ។
៨៥- សូមព្រលឹង របស់ទ្រង់ យល់យល់ជាក់
ភាពស្មោះស្ម័គ្រ របស់យើង ឲ្យបានច្បាស់
ចង់លើកស្នួយ កេរ្តិ៍ឈ្មោះទ្រង់ ឲ្យត្រចះ
កុំឲ្យខ្ចាស់ ដល់ជាតិគេ ដែលលើកទ្រង់ ។
៨៦- ឥឡូវនេះ ទូលបង្គំ មានប្រាថ្នា
លើកជាសារ ធ្វើចុតហ្មាយ ឡើងតម្រង់
ទៅកម្ពុជា តាមរយៈ មន្ត្រីសង្ឃ
ឲ្យលើកទ្រង់ ជា "បុណ្យជាតិ" នៃកម្ពុជា ។
៨៧- សូមទ្រង់ជួយ ស្នួយញត្តិនេះ ឲ្យសម្រេច
តាមបំណាច់ ដែលទ្រង់មាន លើកម្ពុជា
កុំឱ្យឧបសគ្គ មករារាំង ពាំងវេលា
ឲ្យរាជា និងមន្ត្រី គេអនុញ្ញាតិ ។
៨៨- ថ្ងៃអង្គារ ដប់ប្រាំបួន(១៩) ខែមីនា
ឆ្នាំសូន្យពីរ(០២) ត្រីសកា មហាសន្និបាត
សហគមន៍ ព្រះសង្ឃខ្មែរ មកព្រោងព្រាត
គ្រប់ផៅញាតិ ប្រជុំសង្ឃ ពហុកោណ ។
៨៩- នៅក្នុងវត្ត សាមគ្គី រតនារាម
អ៊ុច-ចន្ទមុនី ចៅអារាម រដ្ឋវ៉ាស៊ិងតោន
ក្រោមសង្ឃា ធិបតី នាមសៅ-ឃន
និងសម្តេច ឃោសានន្ទ ជាអម្ចាស់ ។

៩០- ព្រះសង្ឃខ្មែរ គ្រប់ទិសទី សហរដ្ឋ
ពីគ្រប់វត្ត មកប្រជុំ ទាំងក្មេងចាស់
នឹងដោះស្រាយ ហើយរៀបចំ ឲ្យបានច្បាស់
កម្មថ្មីចាស់ ជម្រះសង្ឃ អង្គនានា ។
៩១- គឹម-ច័ន្ទវង្ស ជាចាហ្វាង សារពត៌មាន
កាសែតខ្មែរ ព្រមទាំងមាន សារ៉ូ-ស៊ីវុត្ថា
ខាងនិស្សិត ក្នុងស្រុកខ្មែរ ម៉ី-រដ្ឋា
ឈុន-ដារ៉ា ជាតំណាង សហគមន៏ ។
៩២- បានដាក់ពាក្យ ទៅស្នើ“បុណ្យ ទិវាជាតិ”
សូមព្រះសង្ឃ គ្រប់អស់ញាតិ សហគមន៏
ព្រះសង្ឃខ្មែរ សូមជួយធ្វើ អន្តរាគមន៏
រួចស្នើសុំ ថ្វាយរាជា ទ្រង់អនុមតិ ។
៩៣- រំលឹកគុណ សម្តេចសង្ឃ នាមជួន-ណាត
ជា“បុណ្យជាតិ” ឲ្យពលរដ្ឋ ប្រណិប័តន៏
ធ្វើរាល់ឆ្នាំ ចាំជានិច្ច កិច្ចបញ្ញត្តិ
កុំឲ្យបាត់ អធិគុណ របស់ទ្រង់ ។
៩៤- ក្នុងពេលនេះ សហគមន៏ ព្រះសង្ឃខ្មែរ
បានកែប្រែ ដាក់បញ្ចូល វារអង្គ
“បុណ្យទិវា រំលឹកគុណ សម្តេចសង្ឃ”
ដោយផ្ចិតផ្ចង់ នឹងអនុវត្ត ក្នុងឆ្នាំថ្មី ។
៩៥- ខាងវិទ្យុ អាស៊ីសេរី វីអូអេ
បានសំណេរ ជួយផ្សព្វផ្សាយ រំគាយន័យ
ជួយជម្រុញ កិច្ចការនេះ ឲ្យជោគជ័យ
ទុកដើម្បី រំលឹកគុណ ដ៏ល្បីល្បាញ ។
៩៦- សូមអរគុណ សំ-បូរិន្ទ និងមាស-ចន
ជួយបំប៉ន អត្ថន័យ ដ៏ស្និតស្នាញ
ខំពុះពារ ចុះចាក់ផ្សាយ តាមបណ្តាញ
គឺបង្ហាញ ឲ្យពលរដ្ឋ ដឹងទង្វើ ។

៩៧- ខាងវិទ្យុ ផ្សាយនៅថ្ងៃ ម្ភៃពីរ-បី(២២-២៣)
ខែមីនា យោងតាមន័យ នៃសម្ដី
បើអស់លោក ចង់គាំទ្រ សូមទានផ្ញើ
ទៅវិទ្យុ មានខាងលើ ឲ្យជួយផ្សាយ ។

៩៨- បើលោកអ្នក សមាគម គាំទ្រច្រើន
គឺបង្កើន ឲ្យញត្តិនេះ ឆាប់ពណ្ណរាយ
មានទម្ងន់ ឆាប់អនុមតិ មិនវែងឆ្ងាយ
អ្នកទាំងឡាយ ក៏ឈ្មោះថា ដឹងគុណលោក ។

៩៩- សូមសម្ដី ដែលយើងដាក់ ជាវារៈ
សូមឲ្យបាន ជាសច្ចៈ កើតផលភោគ
ទេវតាជួយ ហើយលើកស្ទួយ ឲ្យមានជោគ
កុំឲ្យមាន ពួកអ្នកមោឃ មករារាំង ។

១០០- ខាងគណបក្ស ខ្មែរអង្គរ សរសេរញត្តិ
ដាក់ថ្វាយថ្វាត់ ជួយគាំទ្រ ឲ្យបានខ្លាំង
សូមសហគមន៍ ព្រះសង្ឃខ្មែរ មានកម្លាំង
នឹងតតាំង ថ្វាយមហាក្សត្រ អង្គរាជា ។

១០១- សហគមន៍ ព្រះសង្ឃខ្មែរ នឹងនិមន្ត
ទៅសម្ពន្ធ ព្រះមហាក្សត្រ ខែឧសភា
យកចុតហ្មាយ ថ្វាយអង្គក្សត្រ ឆ្នាំនេះណា
ថ្វាយទ្រង់ចារ ដាក់រាជវដ្ឋ បានអនុញ្ញាតិ ។

១០២- ថ្ងៃ២២ ខែកញ្ញា ឆ្នាំសូន្យពីរ(០២)
យើងគុម្ពី បីអង្គា ខំសង្វាត
មួយច័ន្ទវង្ស ពីររដ្ឋា និងមួយទៀត
ដូចសាច់ញាតិ គឺសារ៉ូ ស៊ីវុត្ថា ។

១០៣- បានយកញត្តិ ស្នើសុំនេះ ចូលទៅគាល់
នឹងទ្រង់ផ្ទាល់ សិរីវុឌ្ឍ ដូចប្រាថ្នា
សូមទ្រង់ជួយ ជម្រុញញត្តិ ហើយចាត់ការ
ថ្វាយព្រះមហា សីហនុ នរោត្តម ។

១០៤- លោកកុល-ផេង ហើយនិងទ្រង់ ព្រមទទួល
នឹងសម្រួល បន្តការ តាមសួនសម
សូមការនេះ បានសម្រេច មិនបាច់ខំ
សូមឥន្ទ្រព្រហ្ម ជួយជ្រុំជ្រែង គ្រប់ៗគ្រា ។

១០៥- ខែកុម្ភៈ ឆ្នាំ០៣ ថ្ងៃ១៩
គឹម-ច័ន្ទវង្ស បានរៀបក្បួន ចុះលេខា
ធ្វើចុតហ្មាយ ជាថ្មីទៀត ថ្វាយរាជា
តាមអ្នកសារ លោកខៀវ-ហេង បានដំណើរ ។

១០៦- ទៅចូលគាល់ ព្រះមហាក្សត្រ ខែនេះណា
នេះជាសារ លើកទីបី បានដាក់ស្នើ
សូមសម្តេច សីហនុ ទ្រង់សម្តើ
ជូនទៅលើ សភាជាតិ អនុមតិ ។

១០៧- សូមបងប្អូន ជួយព្យាយាម ជួយធ្វើញត្តិ
ថ្វាយមហាក្សត្រ ដើម្បីទ្រង់ នឹងចែងចាត់
បើគ្នាច្រើន ជាកម្លាំង រដ្ឋអាចកាត់
ធ្វើបញ្ញត្តិ បានលឿនឆាប់ អស់សង្ការ ។

១០៨- ថ្ងៃទី១ ខែមេសា ពីរពាន់បី (២០០៣)
ខ្ញុំកវី គឹម-ច័ន្ទវង្ស បានចាត់ការ
ជាមួយលោក ភេម-សុខុន នាយជលសា
យកឯកសារ អង្គសម្តេច ដាក់វិបសាយ ។

១០៩- ភេម-សុខុន លោកពូកែ អ៊ិន្ទឺណិត
លោកខំស្បិត ធ្វើជាវិប ដើម្បីផ្សាយ
ខ្ញុំតែងកាព្យ ជូនអស់លោក ផងទាំងឡាយ
អានសប្បាយ ព្រះជួន-ណាត ប្រវត្តិអង្គ ។

១១០- បើអស់លោក ជាសិស្សគណ ចង់សហការ
មានឯកសារ ថែមបញ្ចូល ប្រវត្តិទ្រង់
ទាក់ទងខ្ញុំ ខ្ញុំនឹងតែង ដោយផ្ចិតផ្ចង់
តាមចំណង់ ដែលអស់លោក ប្រាថ្នាប៉ង ។

១១១- ការដឹងគុណ ជាទ្រព្យធន ដ៏ប្រពៃ
យើងត្រូវលៃ សងគុណលោក ជាសំណាង
គឺប្រវត្តិ រួមគ្រប់ទិស យើងចងក្រង
សូមប្អូនបង ជួយខ្ញុំផង ឲ្យព្រោងព្រាត ។
១១២- សូមជូនពរ ទេពបណ្ដាល ចិត្តគ្រប់គ្នា
កុំចងពៀរ ជម្រុះពាល បាត់វិវាទ
អស់ទំនាស់ ហើយពុះពារ កសាងជាតិ
ខំខ្មីឃ្មាត កុំមុសា ទាំងតូចធំ ។
១១៣- អ្នកណាខ្មៅ ចិត្តកម្មៅ សូមវិនាស
សូមឲ្យរាស្ត្រ ជួបប្រទះ តែសុខដុម
សូមកម្ពុជា បានរុងរឿង មានមនោរម្យ
ដែលយើងខ្ញុំ មានប្រាថ្នា សព្វថ្ងៃនេះ ។

កែសម្រួលបន្ថែមបន្ថយៈ
ថ្ងៃទី២១ខែមីនាឆ្នាំ២០០២
ថ្ងៃទី២២ខែកញ្ញាឆ្នាំ២០០២
ថ្ងៃទី១ខែមេសាឆ្នាំ២០០៣



ចន្ទវង្ស / chanvong

ដោយ គឹម-ច័ន្ទវង្ស

អ្នកនិពន្ធខ្មែរទទួលជ័យលាភីតុរង្វាន់ជំនាន់សុតន្តប្រីជាឥន្ទឆ្នាំ១៩៧៣
សូមទាក់ខ្ញុំបាទតាមរយៈ E-mail: chanvongkim@yahoo.com